# សុន្ទរកថា
# តំណាងអ្នករស់នៅជាមួយមេរោគអេដស៍
# ថ្លែងក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍
# ថ្ងៃ០១ ខែធ្នូ ឆ្នាំ២០១៣

សូមគោរពឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូមគោរពឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងទូត ដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការជាតិ និងអន្តរជាតិជាទីគោរព។

បងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមងាយរងគ្រោះ ដែលមានវត្តមាននៅទីនេះជាទីស្រលាញ់រាប់អាន!

ជំនួសមុខអោយអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមងាយរងគ្រោះ ទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាកិត្តិយសក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមប្រធានបទ "**គ្មានការឆ្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់**" ។

ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព!

នាងខ្ញុំ-ខ្ញុំបាទ ជាអ្នករស់នៅជាមួយមេរោគអេដស៍ម្នាក់ ដែលជំងឺអេដស៍បានបំផ្លាញទ្រព្យសម្បត្តិ សុខភាពគ្រួសារ និងស្ទើរតែជីវិត នាងខ្ញុំ- ខ្ញុំបាទ ផ្ទាល់តែម្តងនៅក្នុងតំណាក់កាលនោះ នាងខ្ញុំ- ខ្ញុំបាទ ទទួលការវាយប្រហារ និងសម្ពាធយ៉ាងខ្លាំងទៅលើផ្នែករូបរាងកាយនិងអារម្មណ៍ រហូតដល់សឹងតែអស់សង្ឃឹមទាំងស្រុងនៅក្នុងជីវិត។ តែដោយសារទទួលបានសេវាថៃទាំនិងព្យាបាលដោយថ្នាំប្រឆាំងមេរោគអេដស៍ដោយឥតគិតថ្លៃ ការអប់រំផ្សព្វផ្សាយពីការលុបបំបាត់ភាពមាក់ងាយនិងការរើសអើង និងសកម្មភាពផ្សេងៗទៀតដើម្បីទប់ស្កាត់ **ការឆ្លងថ្មី ការរើសអើង ការស្លាប់** ដោយមានការចូលរួមពីគ្រប់ស្ថាប័ននិងវិស័យរបស់រាជរដ្ឋាភិបាល ស្ថាប័នដៃគូអភិវឌ្ឍន៍និងម្ចាស់ជំនួយនានា រូបនាងខ្ញុំផ្ទាល់ក៏ដូចជាអ្នករស់នៅជាមួយមេរោគអេដស៍ទាំងអស់ អាចបន្តរស់រានមានជីវិតជាថ្មីម្តងទៀត ដើម្បី

រៀបចំគ្រួសារ និងផែនការអនាគត។ យើងខ្ញុំអាចនិយាយបានថា នេះប្រៀបដូចជាការរស់ឡើងវិញ ឬជាជីវិតទីពីរដែលយើងខ្ញុំអាចមើលឃើញនិងមានសង្ឃឹមជាថ្មីដើម្បីចូលរួមចំណែកស្តារធនធាន ការអភិវឌ្ឍន៍ និងភាពរីកចំរើនសេដ្ឋកិច្ចកម្ពុជា។

លើសពីនេះទៅទៀត សព្វថ្ងៃអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមងាយរងគ្រោះ ក៏ទទួលបានការលើកទឹកចិត្ត និងការឧបត្ថម្ភគាំទ្រផ្នែកសេវានិងសេដ្ឋកិច្ចឡើងវិញ ក្នុងនេះគឺមានន័យថាយើងបានចូលរួមចំណែកកាត់បន្ថយផលប៉ះពាល់របស់កុមាររងគ្រោះនិងងាយរងគ្រោះដោយសារមេរោគអេដស៍និងជំងឺអេដស៍ផងដែរ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការសំណូមពរដល់រាជរដ្ឋាភិបាល តាងនាមតំណាងអោយអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមងាយរងគ្រោះសូមអំពាវនាវឱ្យរាជរដ្ឋាភិបាល ស្ថាប័នដៃគូអភិវឌ្ឍន៍ និងស្ថាប័នម្ចាស់ជំនួយ នៅតែបន្តជួយផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងឱសថប្រឆាំងនឹងមេរោគអេដស៍ដែលមានគុណភាពនិងមានភាពងាយស្រួល គឺមានន័យថាមិនមានផលរំខានច្រើនដល់អ្នករស់នៅជាមួយមេរោគអេដស៍ដោយឥតគិតថ្លៃ សូម្បីតែថ្លៃសេវាពិគ្រោះនិងព្យាបាល សូមឱ្យកិច្ចការនេះនៅតែបន្តប្រឹងប្រែងដល់ក្រុមអ្នករស់នៅជាមួយមេរោគអេដស៍និងក្រុមងាយរងគ្រោះទាំងផ្នែកសេវាថែទាំសុខភាពបន្ថែមទៀតដោយមិនចាំបាច់បង់ថ្លៃសេវាព្យាបាលនៅមន្ទីរពេទ្យ និងជួយឧត្តម្ភទាំងស្មារតី សម្ភារៈអាហារ និងជំនាញវិជ្ជាជីវៈការងារ សំរាប់បន្តការរស់នៅប្រកបដោយគុណភាពជីវិត ពីព្រោះបច្ចុប្បន្ន បរិបទនៃមេរោគអេដស៍បានផ្លាស់ប្តូរ ពីស្ថានភាពរស់នៅទន់ខ្សោយមានការស្អប់ខ្ពើម មកភាពប្រសើរឡើងវិញ ដូចនេះការអប់រំ ការថែទាំ ការអនុវត្តគម្រោង ការផ្តល់ជំនាញ ក៏ត្រូវតែបទបែនទៅតាមស្ថានភាពបច្ចុប្បន្ន លើសពីនេះការបន្តការយកចិត្តទុកដាក់ពីអង្គការជាតិ អន្តរជាតិ ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ជាកត្តាជួយជំរុញ លើកកំពស់សិទ្ធិរបស់អ្នករស់នៅជាមួយមេរោគអេដស៍ឱ្យចាកផុតពីមាក់ងាយនិងការរើសអើង ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ទាំងនៅកន្លែងធ្វើការ និងសហគមន៍ដែលពួកគាត់កំពុងរស់នៅផងដែរដោយស្របជាមួយយុទ្ធសាស្ត្ររបស់ថ្នាក់ជាតិ និងពិភពលោកកំពុងតែខិតខំប្រឹងប្រែងដើម្បី" **គ្មានការឆ្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់** "។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមសម្តែងការអរគុណដល់គ្រប់ស្ថាប័នទាំងអស់ដែលធ្វើការងារអេដស៍ ជាពិសេសដល់រាជរដ្ឋាភិបាលកម្ពុជាដែលជាប្រមុខក្នុងកិច្ចការងារនេះនិងទទួលបានភាពជោគជ័យក្នុងការផ្តល់សេវាថែទាំនិងព្យាបាលដល់អ្នករស់នៅជាមួយមេរោគអេដស៍ ទាំងនេះសបង្ហាញអោយឃើញពីការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីជួយអាយុជីវិត និងរំលែកទុក្ខលំបាករបស់ប្រជាពលរដ្ឋ យើងខ្ញុំជាតំណាងឱ្យបងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ និង

ក្រុមងាយរងគ្រោះ ក្នុងប្រទេសកម្ពុជា មានកិត្តិយស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាពិសេស កាកបាទក្រហមកម្ពុជា ព្រមទាំងអង្គការជាតិ អន្តរជាតិ ដែលបានខិតខំប្រឹងប្រែង យកចិត្តទុកដាក់ ពិនិត្យនិងថែទាំព្យាបាលសុខភាព និងផ្តល់ការគាំទ្រ ទាំងផ្នែកសម្ភារៈ ស្មារតី និងសង្គម ដល់អ្នករស់នៅជាមួយមេរោគអេដស៍អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ធ្វើអោយប្រទេសកម្ពុជាមានការទទួលស្គាល់នៅក្នុងឆាកជាតិនិងអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍និងជំងឺអេដស៍ ដែលជាលទ្ធផលយើងឃើញមានការធ្លាក់ចុះយ៉ាងខ្លាំងនៃអត្រាការឆ្លងមេរោគអេដស៍មកនៅត្រឹម០.៧ភាគរយនៅឆ្នាំ២០១២។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ជួបប្រទះនឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!